# I - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៨៥ អនក្រ.បក.**

**ស្តីការបង្កើតគណៈកម្មការជាតិ សេដ្ឋកិច្ចសង្គម**

**សំរាប់អាស៊ី និង ប៉ាស៊ីហ្វិក (ESCAP)**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆាំ ១៩៩៤
- យោងតាមសំណូមពរចាំបាច់នូវការងាររបស់អង្គការ ESCAP " Escap National Committee "
- តាមសំណើរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី–រដ្ឋមន្ត្រី ក្រសួងសាធារណការនិងដឹកជញ្ជូន

**សំរេច**

**មាត្រា ១** : បង្កើតគណៈកម្មការមួយ មានឈ្មោះហៅថា «គណៈកម្មការជាតិសេដ្ឋកិច្ចសង្គម សំរាប់អាស៊ីនិង ប៉ាស៊ីហ្វិក (ESCAP) ។

**មាត្រា ២ :** គណៈកម្មការនេះ រួមមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១–តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | ជាប្រធាន |
| ២–តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ៣–តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| ៤–តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ជាសមាជិក |
| ៥–តំណាងក្រសួងគ្រប់គ្រងបរិដ្ឋាន | ជាសមាជិក |
| ៦–តំណាងក្រសួងផែនការ | ជាសមាជិក |
| ៧–តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៨–តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៩–តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ជាសមាជិក |
| ១០–តំណាង ESCAP នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងបាងកក ប្រទេសថៃឡង់ដ៍ | ជាសមាជិក |

**មាត្រា ៣ :** គណៈកម្មការជាតិសេដ្ឋកិច្ចសង្គម សំរាប់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP)មានភារកិច្ចនឹងសម្របសម្រួលជាមួយបណ្តាក្រសួងដែលពាក់ព័ន្ធក្នុងការប្រមូលផ្តុំគំនិត លើកសំណូមពរណា ដែលពាក់ទាក់ទងលើវិស័យអភិវឌ្ឍន៍ និងស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធនៅរាជាណាចក្រកម្ពុជា ហើយនិងតាមដានការរីកចំរើន និងសកម្មភាពរបស់អង្គការនេះ ។

**មាត្រា ៤ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខានិងត្រា** | **ហត្ថលេខា និង ត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* *